# សៀវភៅ

# របាយការណ៍សង្ខេប
# ឆ្នាំ២០១៣



## ក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ
## ខេត្តកំពង់ធំ

គណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ
(គ.ព.អ.ល)

រក្សាសិទ្ធិ © ២០១៣ សីលការ ភ្នំពេញ

បោះពុម្ពលើកទី១ ចំនួន ៣០០ក្បាល

ឧបត្ថម្ភដោយ

CIPE

គណៈកម្មការចងក្រងសៀវភៅ អង្គការសីលការ និងអង្គការម៉ូដ

| | |
|---|---|
| អ្នករៀបរៀង និងត្រួតពិនិត្យ | លោកស្រី ធីដា ឃឹះ |
| | លោកស្រី ហាុង សុវណ្ណនី |
| អ្នករៀបចំ និងរចនាសៀវភៅ | លោក ឆាយ ពិទូរ្យ |
| | លោក ចាន់ ប៊ុនធឿន |
| | លោក ស៊ិន សឿប |
| | លោក សារ៉េន នភាភក្តី |
| គាំទ្រដោយផ្នែករដ្ឋបាល | លោក អ៊ុំ ផាន់ណា |

បោះពុម្ពលើកទី១ ឆ្នាំ២០១៣ ចំនួន៣០០ក្បាល
@រក្សាសិទ្ធិដោយអង្គការសីលការ
គាំទ្រថវិកាដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់សហគ្រាសឯកជន (CIPE)

# មាតិកា

I . ផ្នែកទី១
ក-លិខិតសំណើរបស់អង្គការសីលការ
ខ-លិខិតអនុញ្ញាតរបស់ក្រសួងមហាផ្ទៃ
គ-លិខិតអនុញ្ញាតរបស់អភិបាលខេត្តកំពង់ធំ
ឃ-អារម្ភកថា
ង-សារពីអភិបាលរងខេត្តកំពង់ធំ
ច-សារពីអភិបាលរងក្រុងស្ទឹងសែន
ឆ-សារពីអភិបាលរងស្រុកកំពង់ស្វាយ
ជ-បុព្វកថា
II. ផ្នែកទី២
ក. ការបង្កើត គណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចថ្នាក់ក្រោមជាតិ (គ.ព.អ.ល)
-គណៈកម្មការប្រជុំជ្រើសរើស គ.ព.អ.ល
-សមាសភាព គ.ព.អ. ល (បញ្ជីឈ្មោះ គ.ព.អ.ល)
-តួនាទី ទស្សនវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃ របស់គ.ព.អ. ល
-វគ្គបណ្តុះបណ្តាលសំរាប់ គ.ព.អ. ល
-ប្រជុំប្រចាំខែ គ.ព.អ. ល
-ការប្រជុំបូកសរុបប្រចាំឆ្នាំ
ខ. ការផ្សព្វផ្សាយ
-យុទ្ធនាការផ្សព្វផ្សាយ
-ការប្រជុំផ្សព្វផ្សាយគម្រោង(ការប្រជុំតាមឃុំ តាមភូមិ និងជាមួយវិស័យឯកជន)
-ការចងបដា
គ. ការចុះសង្កេតការដេញថ្លៃ និងការប្រជុំពិគ្រោះយោបល់ គ.ព.អ.ល
ឃ.ការចុះស្រង់មតិ
ង.ទីស្នាក់ការរបស់ គ.ព.អ.ល
ច.កិច្ចសហកាអង្គការសីលការ និងអង្គការម៉ូដ

# សីលការ

ទ្រទ្រង់ការរីកចំរើននៃស្ថាប័នឱ្យមានប្រសិទ្ធិភាព និងនិរន្តរភាព តាមរយៈការហ្វឹកហ្វឺនដោយសមរម្យ
Improving Organization Effectiveness and Sustainability through Appropriate Training

លេខ : 7966.សលក

**សូមគោរពជូន**
**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី នៃក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** : សំណើសុំការគាំទ្រ និងការសហការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តគម្រោងសាកល្បង **"ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ"** នៅសាលាខេត្តកំពង់ធំ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានរយៈពេល ១២ខែ គិតចាប់ពី ខែកក្កដា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៣។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា អង្គការ **សីលការ** បានសហការជាមួយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់សហគ្រាសឯកជន **(Center for International Private Enterprise, CIPE)** ហើយបានរៀបចំគម្រោងសាកល្បងមួយដែលមានឈ្មោះថា **"ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ"** ដែលគ្រោងនឹងអនុវត្ត នៅសាលាខេត្តកំពង់ធំ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ គម្រោងនេះមានគោលបំណង ដើម្បីបង្កើនសមត្ថភាព និងការយល់ដឹងជាមូលដ្ឋាន ស្តីពីប្រពន្ធ័ច្បាប់ដែលពាក់ពន្ធ័នឹងដំណើរការកិច្ចលទ្ធកម្មសាធារណៈ ដល់ភាគីពាក់ពន្ធ័សម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងសេវាទីប្រឹក្សា តាមរយៈការប្រើប្រាស់មូលនិធិឃុំ/សង្កាត់ ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ការសន្សំសំចៃខ្ពស់ និងទាន់ពេលវេលា សំដៅកាត់បន្ថយ និងទប់ស្កាត់ការប្រើប្រាស់មូលនិធិសាធារណៈមិនបានចំទិសដៅ ដែលជាចំណុចមួយជួយដល់រាជរដ្ឋាភិបាល ក្នុងការពង្រឹងអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន។

អាស្រ័យសេចក្តីដូចបានជម្រាបជូនខាងលើ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងផ្តល់ការគាំទ្រ និងជួយសហការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យការអនុវត្តគម្រោងសាកល្បង **"ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ"** នេះ ទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួល នូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២

**ហត្ថលេខា**

**ធីដា ខេង**
**នាយិកាប្រតិបត្តិអង្គការសីលការ**

**ជូនភ្ជាប់** :
- កិច្ចព្រមព្រៀង រវាងអង្គការ សីលការ និង មជ្ឈមណ្ឌលអន្តរជាតិ សម្រាប់សហគ្រាសឯកជន
- ផែនការសកម្មភាពគម្រោង
- ស.ជ.ណ លេខ ៤១៦ ស្តីពី ការបង្កើតអង្គការសីលការ
- លក្ខន្តិកៈអង្គការសីលការ

P.O. Box 821, #6S, Street 21, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia | H/P : 012 79 23 79
Tel: (855) 23 217 872/210 902 | Fax: (855) 23 213 108 | E-mail: silaka@silaka.org | Website: www.silaka.org

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ១៣៩៥ សជណ

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២

**ជម្រាបមក**

**លោកស្រី ធីដា ឃិះ នាយិកាប្រតិបត្តិអង្គការសីលការ**

**<u>កម្មវត្ថុ</u>** : ករណីសំណើសុំការគាំទ្រ និងសហការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តគម្រោងសាកល្បង **“ពង្រឹងអភិបាលកិច្ចល្អលទ្ធកម្មថ្នាក់ក្រោមជាតិ”** នៅសាលាខេត្តកំពង់ធំ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**<u>យោង</u>** : លិខិតលេខ ៧៩៦៦ ស.ល.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ របស់អង្គការសីលការ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបមក **លោកស្រីនាយិកា**ថា ក្រសួងមហាផ្ទៃ ឯកភាពជាគោលការណ៍អនុញ្ញាតឱ្យអង្គការសីលការអនុវត្តគម្រោងសាកល្បង **“ពង្រឹងអភិបាលកិច្ចល្អលទ្ធកម្មថ្នាក់ក្រោមជាតិ”** នៅសាលាខេត្តកំពង់ធំ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានរយៈពេល១២ខែ គិតចាប់ពីខែកក្កដា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៣ ដើម្បីបង្កើនសមត្ថភាព និងការយល់ដឹងជាមូលដ្ឋាន ស្តីពីប្រព័ន្ធច្បាប់ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការលទ្ធកម្មសាធារណៈ ដល់ភាគីពាក់ព័ន្ធសម្រាប់ការទិញ ការសាងសង់ ការផ្គត់ផ្គង់ ការជួលសេវាកម្ម និងសេវាទីប្រឹក្សា តាមរយៈការប្រើប្រាស់មូលនិធិឃុំ សង្កាត់ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ការសន្សំសំចៃខ្ពស់ និងទាន់ពេលវេលា សំដៅកាត់បន្ថយ និងទប់ស្កាត់ការប្រើប្រាស់មូលនិធិសាធារណៈមិនបានចំទិសដៅ ដែលជាចំណុចមួយជួយដល់រាជរដ្ឋាភិបាលក្នុងការពង្រឹងអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាន។ ក្នុងការអនុវត្តគម្រោងនេះ អង្គការសីលការត្រូវសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីរៀបចំឯកសារពាក់ព័ន្ធក្នុងការអនុវត្តគម្រោងនេះ ព្រមទាំងត្រូវផ្ញើរបាយការណ៍សកម្មភាពការងារ និងលទ្ធផលសម្រេចបានមកក្រសួងមហាផ្ទៃកុំបីខាន។

អាស្រ័យហេតុនេះ សូម**លោកស្រីនាយិកា** ជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើ តាមការគួរ។

សូម លោកស្រីនាយិកា ទទួលនូវការរាប់អាន ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីជ្រាបជាព័ត៌មាន)
- សាលាខេត្តកំពង់ធំ
  (ដើម្បីចូលរួមសហការ)
- ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣៧២៦០៥២-២៣៧២៦០៥៣

ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ email: moi@interior.gov.kh Web: www.interior.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**សាលាខេត្តកំពង់ធំ**
លេខ: ៤០១....ស.ជ.ណ

កំពង់ធំ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១២

**អភិបាលខេត្ត**
**ជម្រាបមក**
**លោក នាយកអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

**កម្មវត្ថុ:** ករណីសុំការគាំទ្រ និងសុំអនុញ្ញាតអនុវត្តគម្រោងសាកល្បង ពង្រឹងអភិបាលកិច្ចល្អ លទ្ធកម្មថ្នាក់ក្រោមជាតិ នៅក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

**យោង:**
- លិខិតលេខ: ១០ ស.ជ.ណ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ: ៨២៣ស.ជ.ណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៩៤ របស់សាលាខេត្តកំពង់ធំ
- លិខិតលេខ: ១៣៨៥ ស.ជ.ណ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ
- ចំណារយល់ព្រមរបស់ឯកឧត្តមអភិបាលខេត្ត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបលោកនាយកជ្រាបថា: អភិបាលខេត្តបានពិនិត្យ និងយល់ព្រមឲ្យលោកនាយកចុះអនុវត្តគម្រោងសាកល្បងពង្រឹងអភិបាលកិច្ចល្អ លទ្ធកម្មថ្នាក់ក្រោមជាតិ នៅក្នុងក្រុងស្ទឹងសែន ចំនួន០៣សង្កាត់ គឺ សង្កាត់ស្រយូវ អូរកន្ធរ និងសង្កាត់អាចារ្យលាក់ និងនៅក្នុងស្រុកកំពង់ស្វាយ ចំនួន០៣ឃុំ គឺ ឃុំសានគរ ត្រពាំងឫស្សី និងឃុំកំពង់ស្វាយ គម្រោងនេះមានរយៈពេល១២ខែ ដែលនឹងត្រូវដំណើរការចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣ តាមការស្នើសុំហើយ ។ ប៉ុន្តែក្នុងពេលចុះអនុវត្តគម្រោងជាក់ស្តែង សូមលោកនាយកធ្វើការទំនាក់ទំនងឲ្យបានល្អជាមួយអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធក្នុងខេត្ត ដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឲ្យបានល្អប្រសើរ និងរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តគម្រោងសាកល្បងនេះមកសាលាខេត្ត ។

អាស្រ័យហេតុនេះ សូមលោកនាយកជ្រាប និងអនុវត្តតាមការគួរ ។

សូមលោកនាយកទទួលនូវការរាប់អានអំពីខ្ញុំ ។

**អភិបាលខេត្ត**

យស_ចាន់ណារី

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ទីស្តីការក្រសួងមហាផ្ទៃ
-ក្រុមប្រឹក្សាខេត្ត
"ដើម្បីជូនជ្រាប"
-បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
-ស្នងការដ្ឋាននគរបាលខេត្ត
-សាលាក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ
"ដើម្បីសហការ អនុវត្ត"
-ឯកសារ-កាលប្បវត្តិ



# អារម្ភកថា

"កិច្ចលទ្ធកម្មសាធារណៈ" គឺជាពាក្យមួយថ្មី និងកំពុងពេញនិយម នៅក្នុងព្រះរាជាណាចក្រកម្ពុជា នាសម័យបច្ចុប្បន្ន។ ខ្ញុំយល់ថា លទ្ធកម្មសាធារណៈ ឬការដេញថ្លៃ គឺពិតជាទាមទារនូវឆន្ទៈស្នេហាជាតិ ខ្ពស់នៅក្នុងការអនុវត្តគំរោងនានា ដែលជាសមិទ្ធិផលរបស់ភូមិ ឃុំ សង្កាត់។ បើយើងអនុវត្តកិច្ចការនេះដោយតម្លាភាពខ្ពស់ នោះវានឹងរួមចំណែកលើកកំពស់លទ្ធិប្រជាធិបតេយ្យ និងពង្រឹងបាននូវអភិបាលកិច្ច ល្អនៅថ្នាក់ក្រោមជាតិ ដែលជាស្នូលនៃយុទ្ធសាស្ត្ររាជរដ្ឋាភិបាល។

តាមរយៈសកម្មភាពដែលខ្ញុំបានចូលរួមកន្លងមកនេះ ខ្ញុំពិតជាមានមោទនៈភាព ដោយបានមើលឃើញនូវអ្វីដែលជាការពិត អ្វីដែលមិនទាន់បានត្រឹមត្រូវតាមសៀវភៅណែនាំ ស្តីពីការអនុវត្តន៍គំរោងមូលនិធិឃុំ សង្កាត់ ដែលពលរដ្ឋខ្មែរត្រូវតែចូលរួមទទួលខុសត្រូវ និងជួយកែលំអទាំងអស់គ្នា។ ការផ្តួចផ្តើមគំនិតរបស់លោកស្រី **ធីតា ឃឹះ** នាយិកាអង្គការ សីលការ នៅក្នុងការកាត់បន្ថយភាពអសកម្មនៃដំណើរការលទ្ធកម្មសាធារណៈពិតជាត្រឹមត្រូវណាស់។ម្យ៉ាងទៀត ខ្ញុំក៏សូមកោតសរសើរចំពោះ ការចងក្រងជាសៀវភៅ "**របាយការណ៍សង្ខេប ឆ្នាំ២០១៣ ក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ គណកម្មការពង្រឹង អភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ**" ដ៏មានសារៈសំខាន់នេះដែលនឹងជួយចែករំលែកបទពិសោធន៍ល្អៗទៅដល់អ្នកដែលពាក់ពន្ធ័ ដើម្បីជាប្រទីបកែលំអលើរាល់ការងារដេញថ្លៃ អោយកាន់តែមានប្រសិទ្ធភាពខ្ពស់ និងភាពសក្តិសិទ្ធិ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃខេត្តកំពង់ធំដែលបានគាំទ្រផ្នែកច្បាប់ និងសហការឲ្យគម្រោងនេះដំណើរការបានរលូន និងមជ្ឈមណ្ឌលអន្តរជាតិសំរាប់សហគ្រាសឯកជន (CIPE) ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ការអនុវត្តគំរោង ដែលអាចអោយអង្គការសីលការ និងអង្គការម៉ូដ ទទួលបានជោគជ័យគួរជាទីមោទនៈ។

ចុងបញ្ចប់ ក្នុងនាមគណកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល) ខ្ញុំសូមស្វាគមន៍ចំពោះមតិយោបល់ និងការកែលំអដើម្បីអោយការបោះពុម្ពលើកក្រោយកាន់តែមានភាពប្រសើរឡើងថែមទៀត។

កំពង់ធំ ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១៣

**ប្រធាន គ.ព.អ.ល**

**អុល សំអៀច**



## សារពីអភិបាលរងខេត្តកំពង់ធំ

កិច្ចលទ្ធកម្មសាធារណៈនៅថ្នាក់ក្រោមជាតិ ដែលយើងតែងតែនាំគ្នាហៅថា "ការដេញថ្លៃ" គឺជាការងារមួយ ដែលមានសារៈសំខាន់នៅក្នុងដំណើរការកសាងប្រទេសជាតិ។ តំរូវការទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ដែលមួយចំណែកនៃថវិកានេះ គឺជាថវិកាបដិភាគពីប្រជាពលរដ្ឋ។ នេះសបញ្ជាក់ថា សមិទ្ធិផលទាំងឡាយដែលកើតឡើងពីការដេញថ្លៃ គឺជាញើសឈាមរបស់យើងទាំងអស់គ្នា។ បើយើងទាំងអស់គ្នាមិនបានចូលរួមជាគំនិតយោបល់នៅក្នុងកិច្ចប្រជុំនានាពាក់ពន្ធ័ ការដេញថ្លៃទេនោះ គុណភាពសមិទ្ធិផល គឺពិតជាពុំដូចបំណងប្រាថ្នានោះទេ។

កន្លងមក សំណង់មួយចំនួនដែលកើតឡើងពីការដេញថ្លៃនៅថ្នាក់មូលដ្ឋាន ត្រូវបានខូចខាតទៅវិញជាបណ្តើរៗ បន្ទាប់ពីក្រុមហ៊ុនម៉ៅការបានបញ្ចប់ការងាររបស់គេ។ នេះក៏ដោយសារតែប្រជាពលរដ្ឋយើងមិនបានចូលរួមជួយត្រួតពិនិត្យមើល ហើយព្រះរាជាណាចក្រកម្ពុជាយើងក៏ទើបតែបានអនុវត្ត ការងារលទ្ធកម្ម ឬការដេញថ្លៃនេះនៅក្នុងឆ្នាំ២០០៦តែប៉ុណ្ណោះ។

ឆ្លៀតឱកាសនេះដែរក្នុងនាមអាជ្ញាធរខេត្ត ខ្ញុំសូមអបអរសាទរចំពោះស្នាដៃទាំងឡាយ ដែលអង្គការសីលការ និងអង្គការម៉ូដ បាននិងកំពុងអនុវត្តកិច្ចការដ៏មានសារៈសំខាន់នេះ ដើម្បីចូលរួមចំណែកនៅក្នុងកិច្ចពង្រឹង លិទ្ធិប្រជាធិបតេយ្យ នៅថ្នាក់មូលដ្ឋាន។ កិច្ចការនេះស្មុគស្មាញណាស់ ដោយសារតែវាទាក់ទងនឹងបច្ចេកទេស ច្រើន ហើយគណៈកម្មការចំរុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល) ជាក្រុមការងារមានវ័យក្មេង ខ្ចី បទពិសោធន៍ក៏តិចតួច ហើយពួកគេក៏មិនធ្លាប់បានលើកយក បញ្ហាណាមួយដែលជាប្រយោជន៍រួមមក ដោះស្រាយជាមួយអ្នកដែលពាក់ពន្ធ័ដែរ។ ទោះបីជាគំរោងនេះ ជាគំរោងដែលកំពុងសាកល្បងក៏ដោយ ក៏គំរោងថ្មីនេះនឹងអាចជួយកែលំអនូវភាពអវិជ្ជមាន ដែលតែងតែកើតមានឡើងនៅក្នុងដំណើរការដេញថ្លៃ ឈរលើភាពយុត្តិធមិ ភាពស្មោះត្រង់ និងយកប្រយោជន៍ជាតិជាធំ ហើយក៏មានការគាំទ្រដ៏ពេញទំហឹងពីអាជ្ញាធរ។

ខ្ញុំក៏មានមោទនៈភាពខ្លាំងណាស់ នៅពេលដែលអង្គការសីលការបានបោះពុម្ពសៀវភៅ "របាយការណ៍សង្ខេប ឆ្នាំ២០១៣ ក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ គណៈកម្មការពង្រឹង អភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ" នេះឡើងវាជាសមិទ្ធិផលបង្ហាញពីស្នាដៃរបស់អង្គការ ម៉ូដ និង គ.ព.អ.ល។ ខ្លឹមសារនៃសៀវភៅនេះនឹងជួយផ្សព្វផ្សាយ និងផ្តល់គំនិតបែបស្ថាបនាទៅដល់អង្គភាពរដ្ឋ ឬអ្នកពាក់ពន្ធ័ដ៏ទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្រៅប្រទេសអោយបានយល់ពីទឹកចិត្ត និងលទ្ធផលដែលអង្គការ ឬ គ.ព.អ.ល បានបំពេញតួនាទីនៅក្នុងបុព្វហេតុ លើកស្ទួយលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងភាពជាអ្នកធ្វើការដោយ ស្មគ្រ័ចិត្ត៕

កំពង់ធំ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣

**អភិបាលរងខេត្តកំពង់ធំ**

**យស ថានារី**



# សារពីអភិបាលនៃក្រុងស្ទឹងសែន

សៀវភៅ "របាយការណ៍សង្ខេបឆ្នាំ២០១៣ ក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ គណៈកម្មការពង្រឹង អភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ" ដែលបានបោះពុម្ពឡើងនេះ គឺជាស្នាដៃដ៏ថ្មីស្រឡាងមួយ ដែលសំរេចចេញ ជារូបរាងឡើងអាស្រ័យដោយមានការគាំទ្របច្ចេកទេសពីអង្គការសីលការ និងអង្គការ MODE ពិសេសការផ្តល់ជាមតិល្អៗ ព្រមទាំងបានជួយពិនិត្យ និងកែសំរួលខ្លឹមសារ ពីលោកស្រី **ធីតា ឃីះ** នាយិកាអង្គការសីលការ។

ការងារដេញថ្លៃ ដែលភាសាផ្លូវការនិយាយថា "**កិច្ចលទ្ធកម្មសាធារណៈ**" គឺជាការងារដេញថ្លៃរកអ្នកម៉ៅការមួយដែលមានឆន្ទៈស្នេហាជាតិ មិនមានគំនិតកិបកេង នៅក្នុងការអនុវត្តគំរោងរបស់ខ្លួនឡើយ។ ជាការពិតណាស់ ស្នាដៃនេះក៏មិនអាចខ្វះបាននូវការចូលរួមសហការពីលោក មេភូមិ មេឃុំ ចៅសង្កាត់ អាជ្ញាធរស្រុក ក្រុង និងមន្ត្រីពាក់ពន្ធ័នានា ដែលបានជួយគាំទ្រយ៉ាងសកម្ម ទាំងកំលាំងកាយ ចិត្ត ស្មារតី និងពេលវេលា ដើម្បីអោយ ការងារនេះសំរេចបានជោគជ័យ។

ម្យ៉ាងវិញទៀត យើងខ្ញុំក៏សូមអរគុណចំពោះក្រសួងមហាផ្ទៃ ដែលបានឯកភាព និងអនុញ្ញាតិអោយអង្គការ សីលការ បានសហការអនុវត្ត "គំរោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ" ដែលក្នុងនោះអង្គការ MODE គឺជាអ្នកអនុវត្តផ្ទាល់ ស្របពេលជាមួយក្រុងស្ទឹងសែនកំពុងតែអនុវត្ត "កម្មវិធីច្រកចេញចូលតែមួយ"។

តាមរយៈសៀវភៅរបាយការណ៍នេះ មិត្តអ្នកអានទាំងអស់ នឹងបានយល់ថែមទៀត អំពីកិច្ចលទ្ធកម្មសាធារណៈ ដែលជាប្រពន្ធ័គ្រប់គ្រងធានាអោយមានអភិបាលកិច្ចល្អ ប្រជាធិបតេយ្យ និងមានការចូលរួមពីប្រជាពលរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះមជ្ឈមណ្ឌលអន្តរជាតិសំរាប់សហគ្រាសឯកជន (CIPE) ដែលបានគាំទ្រយ៉ាងពេញទំហឹងដល់ការអនុវត្តគំរោង ដែលអាចអោយអង្គការសីលការ និងអង្គការ MODE ទទួលបានជោគជ័យគួរជាទីមោទនៈ។

ចុងបញ្ចប់ ក្នុងនាមអាជ្ញាធរក្រុង ខ្ញុំសូមស្វាគមន៍ចំពោះមតិយោបល់ និងការកែលំអ ដើម្បីអោយការបោះពុម្ពលើកក្រោយ កាន់តែមានភាពប្រសើរឡើងថែមទៀត។

ក្រុងស្ទឹងសែន ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១៣

**អភិបាលនៃក្រុង**

**ខែក ផា**



# សារពីអភិបាលរងស្រុកកំពង់ស្វាយ

ចាប់តាំងពីឆ្នាំ២០០៦មក រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់មួយ ដែលតំរូវអោយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ គឺឃុំ សង្កាត់ ត្រូវតែអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានដោយម្ចាស់ការ តាមរយៈការផ្ដល់ប្រាក់វិភាជន៍ពីរាជរដ្ឋាភិបាល និងមួយចំណែកតូចនៃថវិកានេះ ជាថវិកាបដិភាគរបស់ប្រជាពលរដ្ឋផងដែរ។ ដោយសារតែការងារដេញថ្លៃជាការងារមួយថ្មី និងមួយអន្លើប្រជាពលរដ្ឋយើង ក៏មិនសូវបានយល់ពីតួនាទីរបស់ខ្លួនដូចនេះការ ចូលរួមយោបល់របស់ពួកគេក្នុងកិច្ចការអភិវឌ្ឍន៍នៅមានកំរិត។

តែពេលនេះខ្ញុំពិតជារំភើបចិត្តក្រៃលែង ដោយបានចូលរួមចំណែកនៅក្នុងការគាំទ្រទៅលើ "**គំរោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ**" ដែលអង្គការ អភិវឌ្ឍន៍ សេដ្ឋកិច្ច ជនបទ (MODE) បាន និងកំពុងអនុវត្តនៅក្នុងឃុំ៣ របស់ស្រុកកំពង់ស្វាយ ដោយមានការគាំទ្របច្ចេកទេសពីអង្គការសីលការ។ តាមរយៈសិក្ខាសាលានៅខេត្តសៀមរាប គំរោងបានបង្ហាញលទ្ធផលដ៏មានផ្លែផ្កា ដែលធ្វើអោយខ្ញុំមានការចាប់អារម្មណ៍ក្រៃលែង ដែលស្នាដៃនេះបានកើតចេញពីការខិតខំប្រឹងប្រែងរបស់អង្គការ MODE ពិសេសពីគណៈកម្មការចំរុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល) ដែលបានព្យាយាម និងយកអស់ស្មារតីរួម នឹងការលះបង់ ពេលវេលាចូលរួមការងារសង្គម ទោះជាគេដឹងថាសមត្ថភាពពួកគេនៅមានកំរិតយ៉ាងណាក៏ដោយ។

ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះក្រសួងមហាផ្ទៃ ដែលបានអនុញ្ញាតអោយអង្គការសីលការបង្កើតគំរោងថ្មី នេះនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីជាការសាកល្បងដំបូង។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម អភិបាលខេត្តកំពង់ធំ ដែលបានអនុញ្ញាតច្បាប់ដល់អង្គការ MODE ចូលរួមនៅក្នុងការសង្កេតទៅលើដំណើរការលទ្ធកម្មក្នុងស្រុកកំពង់ស្វាយ ដែលទង្វើនេះនឹងជួយកាត់បន្ថយនូវភាពអសកម្មនានា ដើម្បីចូលរួមពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។

ជាមួយនេះដែរ តាមរយៈវណ្ណកម្មនេះ យើងសង្ឃឹមថានឹងទទួលបាននូវការរិះគន់ក្នុងន័យស្ថាបនា ពី ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដើម្បីអោយការបោះពុម្ពសៀវភៅលើកក្រោយ កាន់តែមានភាពប្រសើរឡើង។

ស្រុកកំពង់ស្វាយ, ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០១៣

**អភិបាលរងស្រុក**

**អ៊ុត ខណ្ណារ៉ា**

# បុព្វកថា

ក្នុងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ នាខែកញ្ញា ឆ្នាំ២០០០ រដ្ឋជាសមាជិកទាំង១៩៣ បានអនុម័តគោលដៅអភិវឌ្ឍន៍សហវត្សរ៍ ដោយគ្រោងសំរេចឲ្យបាននៅឆ្នាំ២០១៥ នូវគោលដៅ អភិវឌ្ឍន៍សហវត្សរ៍ ចំនួន ០៨ ។

ដោយឡែកកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការបំពេញ គម្លាតរវាងការប្តេជ្ញាចិត្តរបស់ពិភពលោក និងការរីកចំរើនរបស់ជាតិ។ ដើម្បីកាត់បន្ថយគម្លាតរវាងទីក្រុង និងជនបទ ក៏ដូចជាដើម្បីឲ្យប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ ទាំងអស់នៃសង្គមកម្ពុជាទទួលបានសេវាសាធារណៈដូចគ្នា រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលដៅ អភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ចំនួន ០៩ (ដោយបន្ថែមការបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះចូលក្នុង គោលដៅអភិវឌ្ឍន៍សហវត្សរ៍) ។

រាជរដ្ឋាភិបាល ក៏បានរៀបចំអនុម័តក្របខ័ណ្ឌគោលនយោបាយមួយចំនួនសម្រាប់ត្រួសត្រាយ ផ្លូវមានដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការដាក់ចេញនូវ យុទ្ធសាស្រ្ត ចតុកោណ ដែលក្នុងនោះមានអភិបាលកិច្ចល្អជាស្នូល ហើយត្រូវបានទទួលស្គាល់ថា ជាបុរេលក្ខខណ្ឌសំខាន់បំផុតសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌។

អភិបាលកិច្ចល្អអាចសម្រេចទៅបាន លុះត្រាតែមានគណនេយ្យភាពសង្គម ដែលជាកម្លាំងចលករដ៏ចាំបាច់ និងមិនអាចខ្វះបានសម្រាប់ជម្រុញហើយបង្កលក្ខណៈឲ្យពលរដ្ឋអាចចូលរួមធ្វើឲ្យបានអភិបាលកិច្ចល្អ។ ហេតុដូច្នេះហើយទើបសាលាក្រុងស្ទឹងសែន និងសាលាស្រុកកំពង់ស្វាយ បានសហការជាមួយអង្គការសីលការអនុវត្តគម្រោង"ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ" (ព.អ.ល.ថ)ដើម្បីធ្វើឲ្យប្រសើរឡើងអភិបាលកិច្ចលទ្ធកម្មសាធារណៈថ្នាក់ក្រោមជាតិ នៅខេត្តកំពង់ធំ។

ដើម្បីអនុវត្តយុទ្ធសាស្រ្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរាជរដ្ឋាភិបាលបានរៀបចំចង ក្រងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលច្បាប់នេះត្រូវបានប្រកាសឲ្យ ប្រើប្រាស់ដោយព្រះរាជក្រមលេខ

នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៨។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានគោលបំណងកំណត់ការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើតជំរុញ និងធ្វើឲ្យមានចីរភាព ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ។

ដោយយោងលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា ផែនការអភិវឌ្ឍជាតិ ១០ឆ្នាំ សៀវភៅណែនាំស្តីពីការអនុវត្តមូលនិធិឃុំ-សង្កាត់ ដែលបានកែសំរួលលើកទី២ នៅខែមករា ឆ្នាំ២០០៩ ការចុះស្រាវជ្រាវរបស់ អង្គការសីលការអំពីការរៀបចំដំណើរការអនុវត្តគម្រោង ពង្រឹងអភិបាលកិច្ច លទ្ធកម្មថ្នាក់ក្រោមជាតិ គុណតម្លៃរបស់អង្គការសីលការ (ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ ពហុភាពក្នុងសង្គម ការសិក្សាបើកទូលាយ ការជឿជាក់លើ ខ្លួនឯង) និងការគាំទ្រពី អាជ្ញាធរខេត្តកំពង់ធំ ព្រមទាំងការគាំទ្រថវិកាពី មជ្ឈមណ្ឌលអន្តរជាតិសម្រាប់សហគ្រាសឯកជន (CIPE) នាំឲ្យគម្រោងពង្រឹង អភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិបានបង្កើតឡើង និងបានអនុវត្តសាកល្បង ចាប់ពីខែកក្កដា ឆ្នាំ២០១២ ដល់ខែតុលា ឆ្នាំ២០១៣ សំរាប់ឆ្នាំទី១ និងបន្តឆ្នាំទី២ ពីខែវិច្ឆិកា ឆ្នាំ២០១៣ ដល់ខែតុលា ឆ្នាំ២០១៤ និងឆ្នាំទី៣ បន្តពីខែវិច្ឆិកា ឆ្នាំ២០១៤ សំរាប់រយៈពេល១២ខែទៀត នៅក្នុងខេត្តកំពង់ធំ ក្នុងតំបន់គោលដៅចំនួន០២ គឺក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ ដែលមាន ០៦ឃុំ-សង្កាត់ រួមមាន៖ សង្កាត់អូរកន្ធរ សង្កាត់អាចារ្យលាក់ សង្កាត់ស្រយូវ ឃុំកំពង់ស្វាយ ឃុំត្រពាំងឫស្សី និងឃុំសានគរ។ ហេតុនេះហើយបានជាសៀវភៅនេះ ត្រូវបានរៀបចំ និង បោះពុម្ពឡើងក្នុង គោលបំណង: បង្ហាញនូវលទ្ធផលការងារគម្រោងពង្រឹង អភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ រយៈពេលជាង០១ឆ្នាំ (កក្កដា ២០១២-តុលា ២០១៣) ដែលបានអនុវត្តនៅខេត្តកំពង់ធំ។

## ក. ការបង្កើត គណៈកម្មកាចម្រុះពង្រឹងអភិបាលកិច្ចថ្នាក់ក្រោមជាតិ (គ.ព.អ.ល)

### ➢ គណៈកម្មការប្រជុំជ្រើសរើស គ.ព.អ. ល



*ការប្រជុំបោះឆ្នោតជ្រើសរើស គណៈកម្មកាចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល) ដោយសមាជិកគណៈកម្មការទាំង០៥នាក់ (បុគ្គលិកអង្គការសីលការ, អង្គការម៉ូដ, អង្គការ ADHOC, អភិបាលរងក្រុងស្ទឹងសែន និងអភិបាលរងស្រុកកំពង់ស្វាយ) នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ នៅស្នាក់ការអង្គការ ម៉ូដ។*

### ➢ សមាសភាព គ.ព.អ.ល (បញ្ជីឈ្មោះ គ.ព.អ.ល)

សមាជិក គ.ព.អ.ល មាន០៩ នាក់ ក្នុងនោះមានស្ត្រី ០៣នាក់ដូចរាយនាមខាងក្រោម:



ឈ្មោះ អុល សំអៀច
តួនាទី ប្រធាន
តំណាង អង្គការសង្គមស៊ីវិល
លេខទូរស័ព្ទ 012 759 876



ឈ្មោះ អ៊ឹម ឡៃ
តួនាទី អនុប្រធាន
តំណាង ប្រជាពលរដ្ឋ
លេខទូរស័ព្ទ 092 495 044



ឈ្មោះ លាន គន់ឡាំ
តួនាទី សមាជិកអចិន្ត្រៃយ៍
តំណាង អាជីវករ
លេខទូរស័ព្ទ 012 931 809



ឈ្មោះ ជុំ ច័ន្ទពុទ្ធារី
តួនាទី សមាជិក
តំណាង អង្គការសង្គមស៊ីវិល
លេខទូរស័ព្ទ 012 784 122



ឈ្មោះ ផ សុងងី
តួនាទី សមាជិក
តំណាង ក្រុមហ៊ុនឯកជន
លេខទូរស័ព្ទ 077 898 809



ឈ្មោះ ឌឿ យ៉ាន
តួនាទី សមាជិក
តំណាង ប្រជាពលរដ្ឋ
លេខទូរស័ព្ទ 088 850 4486



ឈ្មោះ សេង ប៊ុនហោ
តួនាទី សមាជិក
តំណាង ប្រជាពលរដ្ឋ
លេខទូរស័ព្ទ 088 560 6522



ឈ្មោះ គង់ ផាច
តួនាទី សមាជិក
តំណាង ប្រជាពលរដ្ឋ
លេខទូរស័ព្ទ 017 901 662



ឈ្មោះ អ៊ាង តូ៉រ៉ា
តួនាទី សមាជិក
តំណាង ប្រជាពលរដ្ឋ
លេខទូរស័ព្ទ 089 986 326

**សមាជិក គ.ព.អ.ល បំរុងមាន០៩ នាក់ក្នុងនោះមានស្ត្រី ០៤នាក់ដូចរាយនាមខាងក្រោម:**

១.លោកស្រី ឡុង ឡៃអ៊ាង
២.លោក ជាម សៀង
៣.លោក នួន សំអាង
៤.លោក អង ឆេងអ៊ាន
៥.លោកស្រី ជៀន សុភាព
៦.លោកស្រី យឹម សុខលីម
៧.លោកស្រី ម៉ៅ ម៉ារី
៨.លោក ស៊ុន សៅ
៩. លោក សឿន ពិសិដ្ឋ

## តួនាទី (ការទទួលខុសត្រូវ) របស់ គ.ព.អ.ល

- ប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកិច្ចលទ្ធកម្ម
  - កោះប្រជុំសមាជិកគណ:កម្មការដើម្បីរៀបចំអភិវឌ្ឍផែនការ និងឧបករណ៍សម្រាប់ប្រមូល និងផ្សព្វផ្សាយព័ត៌មានចំពោះដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម
  - ប្រមូលព័ត៌មានអំពីហិរញ្ញវត្ថុ បែបបទកិច្ចលទ្ធកម្មខេត្ត និងឱកាស លទ្ធកម្ម

- រៀបចំសិក្ខាសាលាស្ដីពីដំណើរការការចុះឈ្មោះអ្នកដេញថ្លៃ សំរាប់អាជីវកម្ម ខ្នាតតូច និងមធ្យម
- រៀបចំធ្វើកំណត់ហេតុ និងសរសេររបាយការណ៍

• ធ្វើការសង្កេតលើដំណើរការដេញថ្លៃ
- ប្រជុំកែលំអផែនការ និងពិនិត្យមើលបញ្ជីសម្រាប់ការតាមដានពីដំណើរការកិច្ចលទ្ធកម្ម
- ពិនិត្យមើលពីការដេញថ្លៃតាមដំណាក់កាលនីមួយៗ (ដំណាក់កាលដេញថ្លៃ)
- ប្រជុំឆ្លុះបញ្ចាំង និងប្រមូលរកចំណុចស្លាបនានានា
- រៀបចំការពិគ្រោះយោបល់ជាសាធារណៈ ឬឯកជន
- ប្រជុំកែលំអផែនការ និងសម្ភារៈ
- ផ្ដល់ជូនករណីសិក្សា និងមតិកែលំអ
- ទាក់ទង និងអញ្ជើញអ្នកចូលរួម
- រៀបចំវេទិកាប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន (កម្រិតឃុំ ស្រុក ខេត្ត) ផ្នែកឯកជន និងសហគមន៍ ដើម្បីចែករំលែកពីភាពមិនប្រក្រតីនានាដែលបានកើតឡើងក្នុងដំណើរការដេញថ្លៃ និងពិភាក្សារកដំណោះស្រាយដែលអាចធ្វើបាន សម្រាប់ការធ្វើឲ្យប្រសើរឡើង។
- រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីបញ្ជាក់ពីអ្វីដែលបានរកឃើញ
- រៀបចំរបាយការណ៍ត្រួតពិនិត្យលើដំណើរការកិច្ចលទ្ធកម្ម

• ការប្រជុំ និងវគ្គបណ្ដុះបណ្ដាល
- ប្រជុំគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មរៀងរាល់មួយខែម្ដង
- ប្រជុំប្រចាំត្រីមាសជាមួយអាជ្ញាធរមូលដ្ឋានក្នុងតំបន់គោលដៅរបស់គម្រោង
- វគ្គបណ្ដុះបណ្ដាលរៀបចំដោយអង្គការសីលការ
- វេទិកាសិក្សារៀនសូត្រថ្នាក់ខេត្ត

## ➢ទស្សនវិស័យ បេសកកម្ម គោលដៅ និងគុណតម្លៃរបស់ គ.ព.អ.ល ត្រូវបានប្រជុំអនុម័តនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ នៅខេត្តសៀមរាប

**ទស្សនវិស័យ: គ.ព.អ.ល**

ដំណើរកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ មានការចូលរួមពីប្រជាពលរដ្ឋក្នុងការតាមដាន ត្រួតពិនិត្យវាយតម្លៃ ដោយស្ថាបនា ស្របទៅតាមច្បាប់ ប្រកបដោយ យុត្តិធម៌ មិនលំអៀង ដែលមាន ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈមាន គុណភាព នាំឲ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ជីវភាពប្រជាពលរដ្ឋមានការរីកចំរើន និងមានសុខមាលភាពក្នុងសង្គម ។

**បេសកកម្ម គ.ព.អ.ល**

**គ.ព.អ.ល** ជាកញ្ចក់ឆ្លុះបញ្ចាំងដំណើរការលទ្ធកម្មនៅថ្នាក់ក្រោមជាតិដោយមានស្មារតីឆន្ទៈ និងគោលជំហរម៉ឺងម៉ាត់ ក្នុងការអនុវត្តភារកិច្ច ដើម្បីជាផលប្រយោជន៍រួមរបស់ពលរដ្ឋ ដោយអនុវត្ត បេសកកម្ម ដូចខាងក្រោម:

១. ប្រមូល និងចែកចាយពត៌មានគម្រោងកម្មវិធីលទ្ធកម្ម លទ្ធផល ការត្រួតពិនិត្យ និងប្រើប្រាស់យន្តការគណនេយ្យភាពសង្គម ដែលមានស្រាប់ឲ្យបានដល់ប្រជាពលរដ្ឋ និងសាធារណៈជន ។

២.ត្រួតពិនិត្យ លើការអនុវត្តដំណើរការនិតិវិធីនៃការងារលទ្ធកម្ម ។

៣.ទំនាក់ទំនងល្អ និងសន្ទនា ពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីជុំរុញឲ្យមានការអនុវត្តលទ្ធកម្មឲ្យមានដំណើការស្របទៅតាមនិតិវិធីច្បាប់ដែលបានកំណត់ ។

៤. ពង្រឹងសមត្ថភាពផ្ទៃក្នុង លើនិតិវិធី និងច្បាប់ លទ្ធកម្ម និងជំនាញចាំបាច់ដទៃទៀត ដើម្បីធានាឲ្យមាននិរន្តរភាព នៃអ្នកដឹកនាំ និងអ្នកបច្ចេកទេសថែមទាំងបញ្ចូលអ្នកស្ម័គ្រចិត្តវ័យក្មេង ដោយ គិតពីសមភាពយេនឌ័រ ក្នុង គ.ព.អ.ល ។

**គោលដៅ គ.ព.អ.ល**

រយៈពេល៣ឆ្នាំខាងមុខ គ.ព.អ.ល នឹងសម្រេចបានដូចតទៅ:

- ត្រូវបានទទួលស្គាល់ជាផ្លូវការគាំទ្រ និងសហការពីអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ ក្នុងកិច្ចអនុវត្ត ភារកិច្ចរបស់ខ្លួន ។
- មានសមត្ថភាពអនុវត្តតួនាទីភារកិច្ចនិងសិទ្ធិអំណាចក្នុងការត្រួតពិនិត្យ

វាយតម្លៃការអនុវត្តកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ និងកៀងគរពលរដ្ឋ និងវិស័យឯកជន ឲ្យចូលរួមការងារលទ្ធកម្មឲ្យប្រសើរឡើង ។

- ស្នាដៃ គ.ព.អ.ល ត្រូវបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈការបោះពុម្ព និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

**គុណតម្លៃ គ.ព.អ.ល**

- យុត្តិធម៌មិនលំអៀង មិនរើសអើង
- មិនប្រកាន់និន្នាការនយោបាយ
- ស្ម័គ្រចិត្ត លះបង់ពេលវេលា
- តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព
- ចូលរួមស្ថាបនាតាមច្បាប់
- ប្រកាន់សីល៥
- មុសាវាទ (មិននិយាយកុហកបោកប្រាស់)
- កាមេ (មិនប្រព្រឹត្តិខុសក្នុងផ្លូវកាម)
- អទិន្នាទាន (មិនលួចកេងបន្លំ)
- បាណា (មិនសំលាប់គេ)

**➤ វគ្គបណ្តុះបណ្តាលសំរាប់ គ.ព.អ.ល**



*វគ្គបណ្តុះបណ្តាលអំពី អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និងការអនុវត្តឧបករណ៍គណនេយ្យភាពសង្គម ដើម្បីពង្រឹងអភិបាលកិច្ចលទ្ធកម្មនៅថ្នាក់ជាតិ សម្របសម្រួលដោយអង្គការសើលការ ដល់ បុគ្គលិក ម៉ូដ និង គ.ព.អ.ល មានអ្នកចូលរួម ៨នាក់ ស្ត្រី២នាក់ នៅការិយាល័យអង្គការម៉ូដ នៅថ្ងៃទី១៧-១៨ ខែ មិថុនា ឆ្នាំ២០១៣។*



*វគ្គបណ្តុះបណ្តាលអំពី អភិបាលកិច្ចល្អ គណនេយ្យភាពសង្គម និង ការអនុវត្តឧបករណ៍គណនេយ្យភាពសង្គម ដើម្បីពង្រឹងអភិបាលកិច្ច លទ្ធកម្មនៅថ្នាក់ជាតិសម្របសម្រួលដោយបុគ្គលិកអង្គការ ម៉ូដ ដល់ គ.ព.អ.ល និងក្រុមប្រឹក្សាឃុំ សង្កាត់ មានអ្នកចូល រួម ៩នាក់ ស្ត្រី២ នាក់ នៅការិយាល័យអង្គការ ម៉ូដ នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣។*



វគ្គបណ្តុះបណ្តាលអំពី ការសរសេររបាយការណ៍ សម្របសម្រួលដោយ អង្គការសីលការ ដល់បុគ្គលិកអង្គការ ម៉ូដ មានអ្នកចូលរួម ៣នាក់ នៅស្នាក់ការិយាល័យអង្គការម៉ូដ នៅថ្ងៃទី១៦-១៧ ខែ កក្កដា ឆ្នាំ២០១៣។



វគ្គបណ្តុះបណ្តាលអំពី ការសរសេររបាយការណ៍សម្របសម្រួលដោយបុគ្គលិកអង្គការម៉ូដ ដល់ គ.ព.អ.ល និងក្រុមប្រឹក្សាឃុំសង្កាត់ គោលដៅ មានអ្នកចូលរួម ១៧នាក់ ស្ត្រី៧នាក់នៅការិយាល័យ អង្គការម៉ូដ នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៣។



វគ្គបណ្តុះបណ្តាលអំពីកិច្ចសន្ទនា ពិគ្រោះយោបល់ និងការសម្របសម្រួលដោយអង្គការសីលការ ដល់បុគ្គលិកអង្គការ ម៉ូដ គ.ព.អ.ល មានអ្នកចូលរួម ១៣នាក់ ស្ត្រី៦នាក់ នៅ ការិយាល័យអង្គការម៉ូដ នៅថ្ងៃទី ២៦-២៨ ខែ សីហា ឆ្នាំ ២០១៣។



វគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំ ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដោយគ្រូបណ្តុះបណ្តាល នៃទីចាត់ការ ផែនការវិនិយោគ ខេត្តកំពង់ធំ ដល់បុគ្គលិក សីលការ ម៉ូដ ក្រុមប្រឹក្សាឃុំ និង គ.ព.អ.ល មានអ្នកចូលរួម២៤នាក់ ស្ត្រី៧នាក់នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត កំពង់ធំ ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០១៣។



វគ្គបណ្តុះបណ្តាលអំពីការរៀបចំផែនការយុទ្ធសាស្ត្រ និងការអនុវត្តការងាររបស់គណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ ដល់បុគ្គលិកអង្គការម៉ូដ គ.ព.អ.ល អាជ្ញាធរខេត្តកំពង់ធំ អាជ្ញាធរក្រុងស្ទឹងសែន អាជ្ញាធរស្រុកកំពង់ស្វាយ មន្ត្រីទីចាត់ការ និងវិនិយោគខេត្តកំពង់ធំ មានអ្នកចូលរួម ២៥នាក់ ស្ត្រី៩នាក់រៀបចំដោយអង្គការ សីលការ នៅសណ្ឋាគារ ជាតិថាតាអង្គរ ខេត្តសៀមរាប ថ្ងៃទី ២៤-២៦ ខែ កញ្ញា ឆ្នាំ ២០១៣។

## ➤ ប្រជុំប្រចាំខែ គ.ព.អ.ល

គ.ព.អ.ល ធ្វើការប្រជុំប្រចាំខែចំនួន ០៥លើក នៅក្នុងឆ្នាំ ២០១៣



*ការប្រជុំ លើកទី១ប្រចាំខែមិថុនា ឆ្នាំ២០១៣ នៅ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៣ ដោយមានសមាជិកគ.ព.អ.ល ៨នាក់ ស្ត្រី៣នាក់ នៅស្នាក់ ការអង្គការម៉ូដស្តីពី: ១.ការបង្ហាញពីគោលបំណងប្រជុំ និងយុទ្ធសាស្ត្ររបស់គម្រោង ២.ការបង្ហាញពី របាយការណ៍ និងតួនាទី ភារៈកិច្ចរបស់ គ.ព.អ.ល និងឧបករណ៍ចុះប្រមូលព័ត៌មានកិច្ចលទ្ធកម្ម និង៣.សំណួរ ចម្លើយ និងបិទកម្មវិធីប្រជុំ។*



*ការប្រជុំ លើកទី២ប្រចាំខែកក្កដា ឆ្នាំ២០១៣ នៅ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣ ដោយមានសមាជិកគ.ព.អ.ល ១១នាក់ ស្ត្រី៥នាក់ នៅស្នាក់ការអង្គការម៉ូដស្តីពី: ១.ការបង្ហាញឡើងវិញពីសមាសភាព គ.ព.អ.ល (ពេញសិទ្ធិ និងបំរុង) ២.ការពិភាក្សាជុំវិញការងារ និងតួនាទី គ.ព.អ.ល (ការលំបាក និងដំណោះស្រាយ) និង ៣.ផែនការបន្ត ។*



*ការប្រជុំ លើកទី៣ប្រចាំខែសីហា ឆ្នាំ២០១៣ នៅ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៣ ដោយមានសមាជិកគ.ព.អ.ល ៦នាក់ ស្ត្រី២នាក់ នៅស្នាក់ការអង្គការម៉ូដស្តីពី:*
*១- ការរំលឹក ពីផែនការពីខែមុន,*
*២- ការរៀបចំការបើកយុទ្ធនាការផ្សព្វផ្សាយគម្រោង និងក្បូនដង្ហែ,*
*៣- ការប្រមូលព័ត៌មានសម្រាប់សិក្ខាសាលា និងការចេញដំណើរទៅខេត្តសៀមរាបរបស់ គ.ព.អ.ល និង៤-ផែនការបន្ត ។*



*ការប្រជុំ លើកទី៤ប្រចាំខែកញ្ញា ឆ្នាំ២០១៣ នៅ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១៣ ដោយមានសមាជិកគ.ព.អ.ល ៨នាក់ ស្ត្រី៣នាក់ នៅស្នាក់ការអង្គការម៉ូដស្តីពី: ការបង្ហាញពីគោលបំណង នៃការផ្សព្វផ្សាយគម្រោង ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិនៅតាមភូមិ ឃុំ និងការបែងចែកតំបន់គោលដៅត្រូវចុះពីផ្សព្វផ្សាយ ។*



ការប្រជុំ លើកទី៥ប្រចាំខែតុលា ឆ្នាំ២០១៣ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១៣ ដោយមានសមាជិកគ.ព.អ.ល ៩នាក់ ស្ត្រី៤នាក់ នៅស្នាក់ការអង្គការម៉ូដស្តីពីៈ ១.ការស្វាគមន៍ និងណែនាំឲ្យស្គាល់គ្នា, ២.ការបង្ហាញពីគោលបំណង និងសង្ខេបពី គម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ, ៣.ការអនុវត្តការសម្ភាសន៍ដល់ គ.ព.អ.ល និស្សិត និងអ្នកស្ម័គ្រចិត្ត, ៤.ការបែងចែកតំបន់គោលដៅត្រូវចុះសម្ភាសន៍ ។

### ➢ ការប្រជុំបូកសរុបប្រចាំឆ្នាំ




អង្គការសើលការ បានរៀបចំការប្រជុំបូកសរុបប្រចាំឆ្នាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រ និងការអនុវត្តអនុវត្តការងាររបស់គណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ ដែលមានអ្នកចូលរួមមកពី អង្គការម៉ូដ គ.ព.អ.ល អាជ្ញាធរខេត្តកំពង់ធំ អាជ្ញាធរក្រុងស្ទឹងសែន អាជ្ញាធរស្រុកកំពង់ស្វាយ មន្ត្រីទីចាត់ការ និងវិនិយោគខេត្តកំពង់ធំ សរុបចំនួន២៥នាក់ ស្ត្រី៩នាក់ នៅសណ្ឋាគារជាតិថាតាអង្គរ ខេត្តសៀមរាប ថ្ងៃទី ២៤-២៦ ខែ កញ្ញា ឆ្នាំ ២០១៣។

## ខ. ការផ្សព្វផ្សាយៈ

### ➢ យុទ្ធនាការផ្សព្វផ្សាយៈ



អង្គការសើលការ អង្គការម៉ូដ និងគ.ព.អ.ល បានរៀបចំយុទ្ធនាការសាធារណៈ ស្តីពីសាលាស្រុកកំពង់ស្វាយរីកចំរើនដោយសារលទ្ធកម្មសាធារណៈត្រឹមត្រូវ នៅសាលាស្រុកកំពង់ស្វាយ និងសាលាបឋមសិក្សាព្រៃព្រាល ដែលមានអ្នកចូលរួមមកពីឃុំកំពង់ស្វាយ ឃុំត្រពាំងឫស្សី និងឃុំសានគរ សរុបចំនួន១៤៨នាក់ ស្ត្រី៧០នាក់ នៅ ថ្ងៃទី១៣ ខែ កញ្ញា ឆ្នាំ ២០១៣។



*អង្គការសើលការ អង្គការម៉ូដ និងគ.ព.អ.ល បានរៀបចំយុទ្ធនាការសាធារណៈ ស្ដីពីសាលាក្រុងស្ទឹងសែនរីកចំរើនដោយសារលទ្ធកម្មសាធារណៈត្រឹមត្រូវ នៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ដែលមានអ្នកចូលរួមមកពី សង្កាត់អូរគន្ធរ សង្កាត់អាចារ្យលាក់ សង្កាត់ស្រយូវ សរុបចំនួន១៨៣នាក់ ស្ត្រី៩៤នាក់ នៅ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០១៣។*

## ខ.ការប្រជុំផ្សព្វផ្សាយគម្រោង (ថ្នាក់ខេត្ត ថ្នាក់ឃុំ តាមភូមិ និងជាមួយវិស័យឯកជន)

### ➢ ការប្រជុំផ្សព្វផ្សាយគម្រោងនៅថ្នាក់ខេត្តៈ



*អង្គការសើលការ និងអង្គការម៉ូដ សហការជាមួយអាជ្ញាធរខេត្តកំពង់ធំបានរៀបចំការប្រជុំស្ដីពីការផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ ដល់អាជ្ញាធរក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ ឃុំ-សង្កាត់ មន្ទីរនានា អង្គការសង្គមស៊ីវិល ក្រុមហ៊ុនដេញថ្លៃ និងវិស័យឯកជន នៅសាលប្រជុំមន្ទីរសុខាភិបាល ខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន៣២នាក់ ស្ត្រី០៧នាក់ នៅ ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២។*

### ➢ ការប្រជុំផ្សព្វផ្សាយគម្រោង តាមឃុំគោលដៅៈ



*ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាសង្កាត់អូរគន្ធរ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដល់ក្រុមប្រឹក្សា សង្កាត់ ស្មៀនសង្កាត់ មេភូមិ និងអាជីវករ ដោយមានអ្នកចូលរួមសរុប ១២នាក់ ស្ត្រី០១នាក់ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។*



*ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាសង្កាត់ អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដល់ក្រុមប្រឹក្សាសង្កាត់ ស្មៀនសង្កាត់ មេភូមិ និងអាជីវករ ដោយមាន អ្នកចូលរួមសរុប ១០នាក់ ស្ត្រី០៣នាក់ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២។*



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាសង្កាត់ស្រយូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដល់ក្រុមប្រឹក្សា សង្កាត់ ស្មៀនសង្កាត់ មេភូមិ និងអាជីវករ ដោយមានអ្នកចូលរួមសរុប ២៥នាក់ ស្ត្រី០៤នាក់ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២។



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ មេភូមិ និងអាជីវករ ដោយមានអ្នកចូលរួមសរុប ២៧នាក់ ស្ត្រី ០៤នាក់ នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១២។



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ក្រុម ប្រឹក្សាឃុំ ស្មៀនឃុំ មេភូមិ និងអាជីវករ ដោយមានអ្នកចូលរួមសរុប ២០នាក់ ស្ត្រី០៣នាក់ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២។



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ក្រុម ប្រឹក្សាឃុំ ស្មៀនឃុំ មេភូមិ និងអាជីវករ ដោយមានអ្នកចូលរួមសរុប ៣២នាក់ ស្ត្រី១៨នាក់ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣។

## ➢ ការប្រជុំផ្សព្វផ្សាយគម្រោង តាមភូមិ នៃឃុំគោលដៅ:



ការប្រជុំផ្សព្វផ្សាយ គម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ សម្របសម្រួលដោយ គ.ព.អ.ល នៅសង្កាត់អូរគន្ធរ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដល់ប្រជាពលរដ្ឋដោយមានអ្នកចូលរួមសរុប ១០០នាក់ ស្ត្រី ៧២នាក់ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣។



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ សម្របសម្រួលដោយ គ.ព.អ.ល នៅសង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែនខេត្តកំពង់ធំដល់ប្រជាពលរដ្ឋដោយមាន អ្នកចូលរួមសរុប ៩៤នាក់ ស្ត្រី ៦៨នាក់ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៣។



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ សម្របសម្រួលដោយ គ.ព.អ.ល នៅសង្កាត់ស្រយូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដល់ប្រជាពលរដ្ឋដោយមានអ្នកចូលរួមសរុប ២៥នាក់ ស្ត្រី ០៤នាក់ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៣។



ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ សម្របសម្រួលដោយ គ.ព.អ.ល នៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ប្រជាពលរដ្ឋ ដោយមានអ្នកចូលរួមសរុប ៩៨នាក់ ស្ត្រី៨១នាក់ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៣។



*ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ សម្របសម្រួលដោយ គ.ព.អ.ល នៅឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ប្រជាពលរដ្ឋដោយមានអ្នកចូលរួមសរុប ១០៨នាក់ ស្ត្រី ៧៨នាក់ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៣។*



*ការប្រជុំ ផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ សម្របសម្រួលដោយ គ.ព.អ.ល នៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដល់ប្រជាពលរដ្ឋដោយមានអ្នកចូលរួមសរុប ១០០នាក់ ស្ត្រី ៧៨នាក់ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣។*

### ➢ ការប្រជុំផ្សព្វផ្សាយគម្រោងជាមួយវិស័យឯកជន



*អង្គការសើលការ សហការជាមួយអង្គការម៉ូដ និង គ.ព.អ.ល បានរៀបចំការប្រជុំស្តីពីការផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោម ជាតិ ដល់ក្រុមហ៊ុនដេញថ្លៃ និងវិស័យឯកជន នៅសាលាក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន២៩នាក់ ស្ត្រី០១នាក់ នៅ ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៣។*

## គ.ការចងបដា



*បុគ្គលិកអង្គការម៉ូដ និងគ.ព.អ.ល បានរៀបចំចងបដាផ្សព្វផ្សាយគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅសាលាក្រុងស្ទឹងសែន សាលាស្រុក កំពង់ស្វាយ សាលាឃុំ សាលាសង្កាត់គោលដៅទាំង០៦នៅខេត្តកំពង់ធំ នៅ ថ្ងៃទី១៥-១៦ ខែ សីហា ឆ្នាំ ២០១៣។*

## គ. ការចុះសង្កេតការដេញថ្លៃ និងការប្រជុំពិគ្រោះយោបល់ គ.ព.អ.ល

### ➢ ការចុះសង្កេតការដេញថ្លៃ



*គ.ព.អ.ល និងបុគ្គលិកអង្គការម៉ូដ ចុះសង្កេតការដេញថ្លៃ នៅសាលាក្រុងស្ទឹងសែន នៅថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ ២០១៣។*



*គ.ព.អ.ល និងបុគ្គលិកអង្គការម៉ូដ ចុះសង្កេតការដេញថ្លៃ នៅសាលាស្រុកកំពង់ស្វាយ នៅថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ២០១៣។*

### ➢ ការប្រជុំពិគ្រោះយោបល់ គ.ព.អ.ល



*អង្គការសីលការ សហការជាមួយអង្គការម៉ូដ និងគ.ព.អ.ល បានរៀបចំការប្រជុំស្តីពីការពិគ្រោះយោបល់ពីភាពមិនប្រក្រតីនៃការដេញថ្លៃ នៅសាលា ក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ រវាងក្រុមហ៊ុនដេញថ្លៃ វិស័យឯកជន អាជ្ញាធរក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ សាលាឃុំ-សង្កាត់ទាំង៦ និង គ.ព.អ.ល នៅសាលាក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលមានអ្នកចូលរួមសរុបចំនួន៣៧នាក់ ស្ត្រី១០នាក់ នៅ ថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០១៣។*

### ឃ.ការចុះស្រង់មតិ



*បុគ្គលិកអង្គការសីលការ រៀបចំការប្រជុំណែនាំស្តីពីការចុះស្រង់មតិ សម្រាប់គម្រោង ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ ដល់បុគ្គលិកអង្គការ ម៉ូដ គ.ព.អ.ល និងអ្នកស្មគ្រ័ចិត្ត នៅស្នាក់ការ អង្គការ ម៉ូដ មុនពេលចុះសម្ភាសន៍ ដែលមានអ្នកចូលរួមសរុបចំនួន ៣២នាក់ ស្ត្រី ០៩នាក់ នៅ ថ្ងៃទី២៨ ខែ តុលា ឆ្នាំ ២០១៣។*



*សមាជិក គណៈកម្មការពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល) សម្ភាសបុគ្គលិកអង្គការ COW នៅស្នាក់ការ អង្គការ COW នៅ ថ្ងៃទី៣០ ខែ តុលា ឆ្នាំ ២០១៣។*

### ង.ទីស្នាក់ការរបស់ គ.ព.អ.ល



*ទីស្នាក់ការរបស់គណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅភូមិ ថ្នល់បែក "ក" ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ*

## អង្គការសីលការ

សីលការ គឺជាអង្គការបង្កើនសមត្ថភាពក្នុងស្រុក ដែលមិនប្រកាន់និន្នាការនយោបាយ សាសនា។ អង្គការសីលការ ត្រូវបានចុះឈ្មោះជាអង្គការមិនមែនរដ្ឋាភិបាលនៅក្រសួងមហាផ្ទៃក្នុង ខែមករា ឆ្នាំ១៩៩៧ ។ សីលការ ចង់ឃើញសង្គមកម្ពុជាមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយមានស្ត្រី និងបុរសចូលរួមស្មើគ្នាយ៉ាងសកម្ម ក្នុងអភិបាលកិច្ចសាធារណៈ ដើម្បីសំរេចបាននូវគោលគំនិតនេះ សីលការ បានកសាង និងពង្រឹងសមត្ថភាពពលរដ្ឋកម្ពុជាតាមរយៈ៖ ផ្តល់ការបណ្តុះបណ្តាលសមស្របប្រកបដោយគុណភាព ដើម្បីឆ្លើយទៅនឹង

តម្រូវការ ស្ថាប័នរដ្ឋ និងអង្គការ សង្គមស៊ីវិល ក្នុងគោលបំណង លើកកំពស់អភិបាលកិច្ចល្អ និងសមភាពយេនឌ័រ ដើម្បីកសាងសង្គមកម្ពុជា និងគាំទ្របណ្តាញការងារសហប្រតិបត្តិការ ដើម្បីភ្ជាប់ទំនាក់ទំនងរវាងភាគីដែលមានកាតព្វកិច្ច និងភាគីដែលមានសិទ្ធិទទួល ព្រមទាំងចែករំលែកចំណេះដឹង បទពិសោធន៍ ដើម្បីលើកកំពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាពនៅកម្ពុជា ។

នៅក្នុងខែកក្កដា ឆ្នាំ២០១២ អង្គការសីលការ ដោយមានការគាំទ្រពីមជ្ឈមណ្ឌលអន្តរជាតិ សម្រាប់សហគ្រាសឯកជន បានកំពុងអនុវត្តគម្រោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (ព.អ.ល.ថ) ។គម្រោងនេះមានគោលបំណងសំខាន់គឺធ្វើឲ្យអភិបាលកិច្ចសាធារណៈ នៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជាប្រសើរឡើង។ គម្រោងនេះ នឹងបង្កើនតម្លាភាព និងគណនេយ្យភាព លើកិច្ចលទ្ធកម្មសាធារណៈថ្នាក់ក្រោមជាតិ និងមានទិសដៅសំខាន់បីៈ ទី១ កសាងសមត្ថភាពស្ថាប័នមូលដ្ឋាន ដើម្បីឲ្យគេមានលទ្ធភាពពិនិត្យតាមដានកិច្ចលទ្ធកម្មសាធារណៈប្រកបដោយប្រសិទ្ធភាព និងឆ្លុះបញ្ចាំង ដើម្បីធ្វើការកែលំអ, ទី២ បង្កើនការយល់ដឹងដល់សហគមន៍អាជីវកម្មស្តីពីឱកាស ច្បាប់ វិធាន និង បទបញ្ញត្តិនានាពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ និងទី៣ បង្កើនឲ្យការចូលរួមយ៉ាងខ្ជាប់ខ្ជួនពីសំណាក់ប្រជាពលរដ្ឋ និងវិស័យឯកជន ក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈ។ អង្គការសីលការ បានជ្រើសរើសអង្គការម៉ូដ មកធ្វើជាដៃគូក្នុងការអនុវត្តគម្រោងពង្រឹង អភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិនៅខេត្តកំពង់ធំ ។

## កិច្ចសហការ អង្គការ ម៉ូដ

អង្គការ អភិវឌ្ឍន៍ សេដ្ឋកិច្ច ជនបទ ហៅកាត់ថា "MODE" គឺជាអង្គការក្រៅរដ្ឋាភិបាលខ្មែរមួយ ដែលបានចាប់កំណើតឡើងនៅក្នុងឆ្នាំ ១៩៩៤ នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ ដោយមានការអនុញ្ញាតពីទីស្តីការគណរដ្ឋមន្ត្រី និងមានការយល់ព្រមអោយអនុវត្តការងារពីឯកឧត្តមអភិបាលខេត្តកំពង់ធំផងដែរ។

ដោយសារតែអង្គការ ធ្លាប់មានបទពិសោធន៍លើការងារអភិបាលកិច្ចល្អរួចមកហើយ ទើបអង្គការ សីលការ បានចាប់យកជាដៃគូនៅក្នុងការអនុវត្ត **"គំរោងពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ"** ហៅកាត់ថា **"ព.អ.ល.ថ"**

និងបានអនុវត្តការងារខ្លួន តាំងពីខែតុលា ឆ្នាំ២០១២មកម្ល៉េះ ដែលត្រូវបានកំណត់យកឃុំ៣ក្នុងស្រុកកំពង់ស្វាយ និងសង្កាត់៣ក្នុងក្រុងស្ទឹងសែន ខេត្តកំពង់ធំ ជាឃុំសង្កាត់គោលដៅ។ គោលបំណងសំខាន់របស់គំរោងគឺ ធ្វើយ៉ាងណាអោយផ្នែកអភិបាលកិច្ច សាធារណៈនៅថ្នាក់ក្រោមជាតិ មានភាពប្រសើរឡើង តាមរយៈការបង្កើតអោយមានការចូលរួម សង្កេតការណ៍ពី **"គណៈកម្មការចំរុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ"** ហៅកាត់ **"គ.ព.អ.ល"** ។

**គ.ព.អ.ល** គឺជាក្រុមចំរុះ មានសមាសភាពមកពីអង្គការសង្គមស៊ីវិល អាជីវករ/ក្រុមហ៊ុន និងឯកជន ដែល កើតចេញមកពីការបោះឆ្នោតពីគណៈកម្មការជ្រើសរើសមួយក្រុម (អាជ្ញាធរស្រុក-ក្រុង អង្គការ សីលការ MODE និងអង្គការ ADHOC។ **គ.ព.អ.ល** ត្រូវបានការយកចិត្តទុកដាក់ជួយបណ្តុះបណ្តាលចំណេះដឹង និងមុខជំនាញពីគ្រូមកពីអង្គការសីលការ និងពីមន្ត្រីការិយាល័យផែនការ វិនិយោគខេត្តពាក់ពន្ធ័នឹងការដេញថ្លៃ ក្នុងនោះរួមមាន ច្បាប់លទ្ធកម្ម បទបញ្ញត្តិនានា និងជំនាញនៅក្នុងការសរសេរ របាយការណ៍ ការសំរបសំរួល ការទំនាក់ទំនង និងការពិគ្រោះយោបល់។ ដោយសារតែគំរោងនេះមិនទាន់មានអង្គការណាមួយធ្វើសកម្មភាពនៅឡើយនោះ ជាញឹកញាប់ មន្ត្រីរបស់អង្គការសីលការតែងតែចូលរួម និងសហការជាមួយនឹងបុគ្គលិកគំរោង និងសមាជិក **គ.ព.អ.ល** ដើម្បីជួយកែលំអរាល់ការងារណាដែលនៅខ្វះចន្លោះ ដូចជាការរៀបចំយុទ្ធនាការកិច្ចប្រជុំជាមួយក្រុមហ៊ុន ការពិភាក្សាទៅលើលទ្ធផលដែលបានរកឃើញពីការដេញថ្លៃ ការចងក្រងឯកសារ និងសិក្ខាសាលារៀបចំយុទ្ធសាស្ត្រគំរោង...។ល។ តាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ **គ.ព.អ.ល** មានលទ្ធភាពគ្រប់គ្រាន់ នៅក្នុងការងារអនុវត្តការងាររបស់គេ ដើម្បីជាគំរូល្អ និងចូលរួមចំណែកជួយកែលំអទៅលើដំណើរការ ពង្រឹងអភិបាលកិច្ចអោយកាន់តែមានភាពប្រសើរឡើង។ ជាមួយនេះដែរ អង្គការសីលការ ក៏បានជួយរៀបចំជា របាយការណ៍ដែលបានមកពីការអនុវត្តគំរោង ទុកជាឯកសារ ដើម្បីធ្វើការផ្សព្វផ្សព្វផ្សាយជាសាធារណៈនៅទូទាំងព្រះរាជាណាចក្រកម្ពុជា អោយកាន់តែបានយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន៕



សហការអនុវត្តដោយ

SILAKA

គាំទ្រថវិកា

CIPE

អង្គការសីលការ ផ្ទះលេខ៥៥B-៥៥C, ផ្លូវលេខ៣៩០
សង្កាត់ បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ:០២៣ ២១៧ ៨៧២/០២៣ ២១០ ៩០២/០១២ ៧៩ ២៣ ៧៩
អ៊ីមេល: silaka@silaka.org វិបសាយ: www.silaka.org

អង្គការម៉ូដ ផ្ទះលេខ១៣, ផ្លូវលេខ១ ភូមិកំពង់ធំ
សង្កាត់កំពង់រទេះ, ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ទូរសព្ទ: ០១២ ៩៤៧ ៩២៤
អ៊ីមេល: sinalpeanh@modecambodia.org
វិបសាយ www.modecambodia.org